00244308

A190/I/16

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១)

ចំពោះមុខ:
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៤ ធ្នូ ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 12 / 2008
ម៉ោង (Time/Heure): 9:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak

---

សាធារណៈ:

# សេចក្តីសម្រេចជាលាយលក្ខអក្សរ នៅលើសំណើរដោយផ្ទាល់មាត់របស់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 12 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
Silke STUZINSKY
យុង ផានិត
គីម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

ស សុវាន
Jacques VERGÉS

១. អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានកត់សម្គាល់ពាក្យសុំដោយផ្ទាល់មាត់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នៅក្នុងសវនាការ នាថ្ងៃទី ៤ ខែធ្នូ ឆ្នាំ២០០៨ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធនឹសំណើរសុំបកប្រែសំណុំរឿងរបស់ លោក ខៀវ សំផន និងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គបុរេជំនុំជម្រះ។

២. បញ្ហាលើកឡើងជាបឋមដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការថា វិធានផ្ទៃក្នុងមិនអាចអនុវត្តបានទេ។ អង្គបុរេជំនុំជម្រះបានសម្រេច នៅថ្ងៃទី ២៦ សីហា ២០០៨ នៅក្នុងករណីមោឃភាពនីតិវិធីក្នុងរឿងក្តី "**នួន ជា**"[១] ដែលក្នុងនោះបានផ្តល់ហេតុផលច្បាស់លាស់ថា វិធានផ្ទៃក្នុងគឺនៅជាធរមានចំពោះមុខ អ.វ.ត.ក។ សេចក្តីសម្រេចនេះ មិនត្រូវបានអង្គបុរេជំនុំជម្រះ យកមកធ្វើការពិចារណាសារជាថ្មី ហើយទឡ្ហីករណ៍ផ្ទាល់មាត់ដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីក្នុងថ្ងៃនេះ មិនបានផ្តល់ហេតុផលជូន អង្គបុរេជំនុំជម្រះសម្រាប់ការពិចារណាសាជាថ្មី។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធានផ្ទៃក្នុងនៅជាធរមាន។

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីជនត្រូវចោទបានដាក់ "សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច ដែលបដិសេធចំពោះសំណើសុំឲ្យមានការបកប្រែលើសំណុំរឿង របស់លោក **ខៀវ សំផន**" នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ("សារណាបណ្តឹងឧទ្ធរណ៍")។ សហព្រះរាជ-អាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨។ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍នេះទេ។

៤. នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញ "សេក្តីសម្រេចលើពាក្យសុំឲ្យមានសវនាការជាសាធារណៈរបស់លោក ខៀវ សំផន" ដោយទទួលយកពាក្យសុំ និងបានកំណត់កាលបរិច្ឆេទសវនាការ។

៥. នៅក្នុង "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន" នៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញ នូវសារៈសំខាន់នៃការផ្តល់ការជូនដំណឹងដល់ជនត្រូវចោទជាមុន អំពីសេចក្តីសន្និដ្ឋានមួយចំនួន ដែលត្រូវធ្វើឡើងដោយផ្ទាល់មាត់ក្នុងកំឡុងពេលសវនាការ។ យោងលើគោលការណ៍នៃ

[១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ សីហា ២០០៨, D55/I/8

ការជំនុំជម្រះប្រកបដោយយុត្តិធម៌ អង្គបុរេជំនុំជម្រះបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់សេចក្តីសន្និដ្ឋាន ដើម្បីអាចឲ្យជនត្រូវចោទមានលទ្ធភាពឆ្លើយតប ចំពោះបញ្ហាដែលបានលើកឡើង។[២] គោលការណ៍នេះក៏ជាមូលដ្ឋានសម្រាប់អង្គបុរេជំនុំជម្រះចំពោះ “សេចក្តីបង្គាប់ដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យចំពោះអង្គបុរេជំនុំជម្រះដោយខ្លួនឯង” ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ ដែលអង្គបុរេជំនុំជម្រះបានបង្គាប់ថា “ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាង ដែលបានទាមទារសិទ្ធិថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង នៅក្នុងសវនាការដែលបានរៀបចំធ្វើឡើង គួរធ្វើសំណើជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការពន្យល់អំពីខ្លឹមសារ និងភាពជាប់ទាក់ទងនឹង សេចក្តីសន្និដ្ឋានរបស់ខ្លួនដែលបានលើកឡើង ឲ្យបានយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនសវនាការ”។[៣]

៦. អង្គបុរជំនុំជម្រះយល់ឃើញថា មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីចេតនារបស់ខ្លួនជាផ្លូវការ ក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ក្នុងសវនាការ និងផ្តល់នូវការជូនដំណឹងគ្រប់គ្រាន់អំពីលក្ខណៈនៃសេចក្តីសន្និដ្ឋានរបស់ពួកគេ។ ដោយសារតែវាមិនបានដាក់សំណើពីមុនអង្គបុរជំនុំជម្រះ នឹងមិនស្តាប់នូវសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលសវនាការអំពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នោះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច៖**

បដិសេធសំណើចោល។

ភ្នំពេញ, ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

ប្រាក់ គឹមសាន

[២] សេចក្តីសម្រេចចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន, ២០ មីនា ២០០៨,C11/53 កថាខណ្ឌ ៤៣

[៣] សេចក្តីបង្គាប់ដល់សិទ្ធិរបស់ដើមបណ្តឹង រដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យចំពោះអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ២៩ សីហា ២០០៨, C22/I/69 ទំព័រទី ៤, កថាខណ្ឌ ២